# សេចក្តីថ្លែងការណ៍

## របស់

## សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងជាអគ្គមេបញ្ជាការកងកម្លាំងប្រដាប់អាវុធជាតិកម្ពុជា

រយៈពេលប៉ុន្មានថ្ងៃកន្លងមកនេះបន្ទាប់ពីការផ្តាច់ខ្លួនរបស់ អតីតមេដឹកនាំកំពូលៗរបស់ខ្មែរក្រហម ២ រូប គឺ លោក ខៀវ សំផន និង លោក នួន ជា ចូលមករួមរស់ក្នុងសង្គមជាតិវិញ មានការលេចឡើងនូវប្រតិកម្មចម្រុះ ជាប្រតិកម្មឡកឡឺវាងការសប្បាយនឹងសន្តិភាព ដោយសារអ្នកទាំងពីរខាងលើបានបញ្ចប់សកម្មភាព ធ្វើសង្គ្រាមប្រឆាំងរាជរដ្ឋាភិបាល និង ការមិនសប្បាយចិត្តជាមួយការមិនបានកាត់ទោសដល់មេដឹកនាំខ្មែរក្រហម ដែលបានទទួលខុសត្រូវចំពោះការស្លាប់របស់ប្រជាជនកម្ពុជារាប់លាននាក់ក្នុងរយៈពេលដែលពួកគេកាន់អំណាចពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ។

ព្រមជាមួយនេះ ក៏មានមតិខ្លះនិយាយដល់ការផ្លាស់ប្តូរជំហររបស់ខ្ញុំចំពោះបញ្ហាកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ប្រតិកម្មខាងលើនេះតម្រូវអោយខ្ញុំត្រូវធ្វើការបញ្ជាក់ដូចតទៅ ÷

១ - តាំងពីដើមរៀងមក គ្មានពេលណាមួយដែលខ្ញុំធ្វើការបន្ធូរបន្ថយចំពោះការខិតខំដើម្បីការលុបបំបាត់របបប្រល័យពូជសាសន៍ ប៉ុល ពត ការទប់ស្កាត់កុំអោយរបបនេះវិលត្រឡប់មកជាលើកទី ២ ការទាមទារអោយកាត់ទោសមេដឹកនាំសំខាន់ៗនៃរបបនេះ ការទាមទារអោយសរសេរចូលទៅក្នុងកិច្ចព្រមព្រៀងប៉ារីសអំពីការប្រឆាំងរបបប្រល័យពូជសាសន៍ ការប្រើប្រាស់ដំណោះស្រាយឈ្នះ-ឈ្នះ ដើម្បីសន្តិភាព សមាហរណកម្មក្នុងតំបន់ខ្មែរក្រហមគ្រប់គ្រងដើម្បីសន្តិភាពនៃកម្ពុជា ។ ការប្រឹងប្រែងមិនស្រាកស្រាន្តទាំងនេះ គឺសុទ្ធតែស្ថិតក្នុងគោលដៅបំបាត់ចោលអង្គការចាត់តាំងនយោបាយ និង យោធា របស់ខ្មែរក្រហមទាំងអស់ ។ មកដល់ពេលនេះអាចនិយាយបានថា អង្គការភេរវកម្មមួយនេះត្រូវបានរលាយលើការជាក់ស្តែង ព្រោះគំរាមកំហែងនៃការវិលត្រឡប់នៃរបបប្រល័យពូជសាសន៍ក៏ត្រូវបានបញ្ចប់ សន្តិភាពកើតមានទូទាំងកម្ពុជាដែលជាលើកដំបូង តាំងពីក្រោយសង្គ្រាមលោកលើកទី ២ ដែលអស់មានកម្លាំងប្រដាប់អាវុធខ្មែរក្រហមនៅកម្ពុជា ។

២ - ជាប្រការគួរអោយសោកស្តាយ ដែលអ្នកខ្លះបំភ្លេចអតីតកាល ជាក់ស្តែងនៅឆ្នាំ ១៩៧៩ តុលាការប្រជាជននៃអតីតសាធារណរដ្ឋប្រជាមានិតកម្ពុជាបានកាត់ទោសមេដឹកនាំខ្មែរក្រហម ប៉ុល ពត អៀង សារី ។ កាលនោះខ្ញុំបានរួមជាមួយថ្នាក់ដឹកនាំរបស់គណបក្សប្រជាជន ក្នុងឋានៈជារដ្ឋមន្ត្រីការបរទេស ជាឧបនាយករដ្ឋមន្ត្រី និង ជានាយករដ្ឋមន្ត្រី បានទាមទារយ៉ាងទទូចដោយលើកម្តងហើយម្តងទៀតអោយរំលាយអង្គការចាត់តាំង នយោបាយ យោធារបស់ខ្មែរក្រហមអោយយកមេដឹកនាំខ្មែរក្រហមមកកាត់ទោស តែបែរជាខ្មែរក្រហមបានទទួលសិទ្ធិអង្គុយនៅអង្គការសហប្រជាជាតិ លើអសនៈមួយដែលតំណាងអោយប្រជាជនកម្ពុជារាប់លាននាក់ ដែលទើបបានរួចផុតពីគ្រោះប្រល័យពូជសាសន៍ និង តំណាងអោយព្រលឹងជនជាតិកម្ពុជាជាង ២ លាននាក់ដែលត្រូវខ្មែរក្រហមសម្លាប់ ។ ខ្ញុំនៅចាំបានដោយការឈឺចាប់ថា ឆ្នាំ ១៩៩០ - ១៩៩១ ពេលពិភាក្សាអំពីកិច្ចព្រមព្រៀងប៉ារីស ខ្ញុំគ្រាន់តែសុំអោយគេបញ្ចូលពាក្យ ប្រល័យពូជសាសន៍ប៉ុណ្ណោះ បែរជាខ្ញុំត្រូវទទួលការវាយប្រហារនិងត្រូវចោទប្រកាន់ថា ជាជនគ្មានសុឆន្ទៈក្នុងការបញ្ចប់សង្គ្រាម ។ ខ្ញុំត្រូវទទួលការគៀបសង្កត់ដោយអយុត្តិធម៌ ហើយបង្ខំចិត្តចុះហត្ថលេខាជាមួយមេដឹកនាំខ្មែរក្រហម និង ភាគីកម្ពុជាផ្សេងទៀត ព្រមទាំងប្រទេសហត្ថលេខី នៃកិច្ចព្រមព្រៀងប៉ារីស ។ ពេលនោះ លោក ខៀវ សំផន លោក សុន សេន ដែលឥឡូវនេះគេទាមទារអោយកាត់ទោសនៅពេលដែលម្នាក់ស្លាប់ ម្នាក់ចុះចូលជាមួយរាជរដ្ឋាភិបាល គឺជាអ្នកមានអភ័យឯកសិទ្ធិ នៃក្រុមប្រឹក្សាជាតិជាន់ខ្ពស់កម្ពុជា ។ តើនេះមិនជាសីលធម៌សប្បនិម្មិតក្នុងដំណាក់កាលសង្គ្រាមត្រជាក់ និង ការប្រឈមមុខគ្នានៃមនោគមវិជ្ជាទេឬ ?

ខ្ញុំសូមរំលឹកថា វាជាសំណាងអាក្រក់របស់ខ្មែរក្រហមដែលបានសំរេចធ្វើពហិការមិនចូលរួមក្នុងការបោះឆ្នោត ឆ្នាំ ១៩៩៣ ។ ប្រសិនបើពួកគេចូលរួម ទោះបីបានកៅអីក្នុងសភា ឬ មិនបានក៏ខ្មែរក្រហមក្លាយជាគណបក្សស្របច្បាប់មួយនៅកម្ពុជា ។ កងទ័ព មន្ត្រីរដ្ឋការ របស់ខ្មែរក្រហម នឹង ចូលរួមដោយស្មើភាពក្នុងជីវភាពនយោបាយរបស់ប្រទេស ព្រោះកិច្ចព្រមព្រៀងប៉ារីសតម្រូវអោយបញ្ចូលគ្នានូវអតីតភាគីដែលមានជម្លោះ ទាំងកងទ័ព ទាំងរដ្ឋបាលស៊ីវិល ។ បើសភាពការណ៍វិវត្តន៍បែបនេះ តើនឹងមានអ្នកសីលធម៌សិប្បនិម្មិតប៉ុន្មាននាក់ទាមទារអោយកាត់ទោសមេដឹកនាំខ្មែរក្រហមដូចពេលនេះ ។

ក្រោយការបោះឆ្នោត ឆ្នាំ ១៩៩៣ រាជរដ្ឋាភិបាលអាណត្តិទី ១ បានខិតខំរំលាយខ្មែរក្រហម តាមផ្លូវសន្តិភាព រាប់បញ្ចូលទាំងការលើកលែងទោសអោយលោក អៀង សារី ក្រោមអំណាចសាលក្រមតុលាការ ឆ្នាំ ១៩៧៩ ផង ដើម្បីប្តូរយកសន្តិភាព និង ការបង្រួបបង្រួមជាតិ ។

ក្រោយការបះបោរនៅអន្លង់វែង និង ការស្លាប់របស់ ប៉ុល ពត សង្គ្រាមក៏មិនទាន់បញ្ចប់នៅ ឡើយ យើងបានព្យាយាមបញ្ចុះបញ្ចូលអោយនាយទាហាន ពលទាហានខ្មែរក្រហមបន្តចុះចូល ហើយបានព្យាយាមទាក់ទងមិត្តភក្តិជិតខាងរបស់យើង ដើម្បីអោយគេប្រគល់តាម៉ុក ខៀវ សំផន នួន ជា មកអោយយើង តាំងពីខែ ឧសភា ឆ្នាំ ១៩៩៨ តែមិនបានសំរេច ។ មិត្តភក្តិជិតខាងរបស់យើងដែលរក្សាទុកពួកមេដឹកនាំខ្មែរក្រហម ទាំងថ្នាក់ខ្ពស់ ថ្នាក់ទាប តែងបដិសេធថា គ្មានមេដឹកនាំខ្មែរក្រហមនៅលើទឹកដីរបស់គេទេ តែគេថានឹងប្រគល់អ្នកទាំងនោះអោយយើង ប្រសិនជាយើងទទួលយកអោយមករួមរស់ក្នុងសង្គមជាតិវិញ ។ ខែ មិថុនា ឆ្នាំ ១៩៩៨ យើង សាកល្បងទទួលលោក ចាន់ យ៉ូរ៉ាន់ ,ម៉ក់ បេន ,កោ ប៊ុនហេង ,អ៊ិន សុភាព ជួន ជឿន ឃើញថា ប្រមាណ ៤៨ ម៉ោង ប៉ុណ្ណោះ អ្នកទាំងនេះមកដល់ប៉ៃលិន ។ ចុងក្រោយនេះចំពោះលោក ខៀវ សំផន នួន ជា យើងចំណាយពេលប្រមាណ ៧២ ម៉ោង ក្រុមគ្រួសារអ្នកទាំងពីរក៏មកដល់ប៉ៃលិនទៀត ។ ខ្ញុំគ្រាន់តែបញ្ជាក់ថា ប៉ៃលិនគ្មានអាកាសយានដ្ឋានអន្តរជាតិនាំអ្នកទាំងនេះ ចេញពីប្រទេសមួយមកកាន់ប៉ៃលិនទេ ហើយអ្នកទាំងនេះក៏មិនបានធ្វើដំណើរពីបាត់ដំបងទៅប៉ៃលិនដែរ ពួកគាត់ធ្វើដំណើរតាមរថយន្តពីទឹកដីប្រទេសមួយចូលមកប៉ៃលិន ។ លោក ខៀវ សំផន នួន ជា , ចាន់ យ៉ូរ៉ាន់ , ម៉ក់ បេន ជួន ជឿន , អ៊ិន សុភាព ,កោ ប៊ុនហេង និង មនុស្សច្រើនទៀត ជាសាក្សីរស់ គេអាចសួរគាត់ថា តើគាត់នៅទីណាមុនពេលគាត់ចូលមកកម្ពុជា ។ ខ្ញុំសូមអភ័យទោសចំពោះមិត្តភក្តិទាំងឡាយដែលខ្ញុំត្រូវបង្ខំចិត្តនិយាយការពិត ដើម្បីសីលធម៌ពិតប្រាកដដែលមិនមែនជាសីលធម៌សប្បនិម្មិត ហើយខ្ញុំក៏មិននិយាយពីតាម៉ុក នៅទីណាទេ ប្រសិនគ្មានការចាំបាច់ ។

មុននេះប៉ុន្មានឆ្នាំ ល្បែងសង្គ្រាម និង សន្តិភាពត្រូវបានគេលេងយ៉ាងគគ្រឹកគគ្រេង ទាំងនៅកម្ពុជា ទាំងនៅអង្គការសហប្រជាជាតិ ទាំងនៅសន្និសិទប៉ារីស និង គ្រប់វេទិកាចរចារ រហូតភ្លេចដល់សីលធម៌ និង ផ្លូវច្បាប់ ភ្លេចដល់អនុសញ្ញាស្តីពីការទប់ស្កាត់ និង ផ្តន្ទាទោសអំពើប្រល័យពូជសាសន៍ដែលនៅជាធរមាន ហើយខ្ញុំ ហ៊ុន សែន ក្លាយជាមនុស្សឯកកោ ក៏ព្រោះប្រឆាំងរបបប្រល័យពូជសាសន៍ ។

ថ្ងៃនេះ ហ៊ុន សែន ក៏ត្រូវរងការឈឺចាប់មួយទៀត ដោយសារបានទទួលជោគជ័យក្នុងការរំលាយអង្គការចាត់តាំងនយោបាយ និង យោធា របស់ ប៉ុល ពត បង្កើតបានសន្តិភាពពេញលេញ ជំរុញបានចលនាបង្រួបបង្រួមជាតិ ផ្សះផ្សាជាតិ <u>ហើយភ្លេចនិយាយដល់ការកាត់ទោសខ្មែរក្រហម ។ ប៉ុន្តែខ្ញុំមិនមែនភ្លេចនិយាយទេ តែមិនទាន់និយាយដល់ ព្រោះខ្ញុំត្រូវនិយាយពីសន្តិភាពជាមុន</u> ដោយសារ ជាតិ និង ប្រជាជនត្រូវការសន្តិភាពជាមុន ។

វាជារឿងគួរអោយចង់សើច ហើយក៏មិនពិបាកសំរាប់មនុស្សដែលខ្វះស្មារតីទទួលខុសត្រូវដែលជាប្រភេទពួកសីលធម៌សិប្បនិម្មិត ឬ ពួកឱកាសនិយមខាងនយោបាយ ។ ពាក្យខ្មែរបុរាណលោកពោលថា

ក្របីស៊ីស្រូវ បងមិនហ៊ានដេញ ក្របីដើរចេញ បងដេញអោយស្រីមើល ក្រពើក្នុងទឹក បងមិនហ៊ានចាប់ ក្រពើងាប់ស្រាប់ បងចាប់អោយស្រីមើល ។ ពេលខ្មែរក្រហមនៅខ្លាំងទាំងនយោបាយ និង យោធា តែការជាការគំរាមកំហែងពិតប្រាកដ គេអោនក្បាលទទួលខ្មែរក្រហម សូម្បីតែពាក្យប្រល័យពូជសាសន៍ក៏មិនហ៊ានប្រើផង ។ ពេលយើងលើកទ័ពវាយខ្មែរក្រហម គេថ្កោលទោសយើង ហើយផ្តល់ការគៀបសង្កត់អោយយើងធ្វើការចរចារអោយខ្មែរក្រហមមកចូលរួមបោះឆ្នោត តាមរយៈគណបក្សមហាសាមគ្គីជាតិរបស់ ខៀវ សំផន ហើយថែមទាំងសុំអោយលើកលែងទោសមេដឹកនាំខ្មែរក្រហមទៀតផង ប៉ុន្តែមនុស្សដដែលនេះបានថ្កោលទោសយើង ពេលយើងទទួល ខៀវ សំផន , នួន ជា អោយមកចូលរួមក្នុងសង្គមជាតិវិញ ដែលអ្នកទាំងពីរមិនបាននាំមកជាមួយនូវអង្គការចាត់តាំងខ្មែរក្រហមទេ គឺមករួមរស់ក្នុងសង្គមជាតិ ជាពលរដ្ឋសាមញ្ញ ។ និយាយអោយចំ មនុស្សប្រភេទនេះ សោកស្តាយយ៉ាងខ្លាំងចំពោះមុខការរលំរលាយនៃអង្គការខ្មែរក្រហម ព្រោះអស់ខ្មែរក្រហមសំរាប់ធ្វើជាកូនជញ្ជីងខាងនយោបាយដើម្បីប្រឆាំងរដ្ឋាភិបាលតទៅទៀត ។

ឥឡូវនេះ ខ្ញុំត្រូវបញ្ជាក់នូវគោលជំហររបស់ខ្ញុំជុំវិញការកាត់ទោសខ្មែរក្រហម ។ គ្មានការផ្លាស់ប្តូរណាមួយក្នុងជំហររបស់ខ្ញុំឡើយ ។ ជំហររបស់ខ្ញុំការកាត់ទោសខ្មែរក្រហមជារឿងហើយស្រេចនិងជាបញ្ហាត្រូវបន្ត ។ ជារឿងហើយស្រេច គឺសាលក្រមតុលាការប្រជាជនឆ្នាំ ១៩៧៩ នៅតែមានតម្លៃ ដែលត្រូវបានទទួលស្គាល់ដោយព្រះរាជក្រឹត្យលើកលែងទោសអោយលោក អៀង សារី កាលពីឆ្នាំ ១៩៩៦ ។ ជាបញ្ហាត្រូវបន្ត គឺតុលាការមួយដែលត្រូវបង្កើតឡើងផ្អែកតាមយោបល់របស់អ្នកច្បាប់អន្តរជាតិ និង ជាតិ ដែលកំពុងធ្វើកិច្ចការរបស់គេ ។ ខ្ញុំជាមនុស្សម្នាក់ ក្នុងចំណោមមនុស្សដែលគាំទ្រការស៊ើបអង្កេតបទឧក្រិដ្ឋនៃរបបប្រល័យពូជសាសន៍ ប៉ុល ពត ដែលជាចំខាតត្រូវផ្តន្ទាទោស តែខ្ញុំក៏មិនធ្វើជាអ្នកចោទប្រកាន់មនុស្សនេះ ឬ មនុស្សនោះ ជំនួសព្រះរាជអាជ្ញាអមតុលាការនោះទេ ។ យើងត្រូវរកចម្លើយអោយសំនួរជាច្រើនរួមមាន តើត្រូវបង្កើតតុលាការបែបណា តុលាការជាតិ ឬ តុលាការអន្តរជាតិ ទីតាំងតុលាការនៅកម្ពុជា ឬ នៅបរទេស ចៅក្រម និង ព្រះរាជអាជ្ញាខ្មែរ ឬ បរទេស ឬ ចម្រុះគ្នាខ្មែរ និង បរទេស ជំនុំជំរះតាមច្បាប់ខ្មែរ ឬ ច្បាប់អន្តរជាតិ ។ល។ និង ។ល។ តាមការយល់ដឹងបន្តិចបន្តួចរបស់ខ្ញុំ គឺមានតែព្រះរាជអាជ្ញាប៉ុណ្ណោះ ទើបមានសិទ្ធិចោទប្រកាន់បុគ្គលនេះ ឬ បុគ្គលនោះ យើងជាអ្នកនយោបាយ គួរគិតសកម្មភាពខ្លួនត្រឹមភារកិច្ចដែលខ្លួនមានបានហើយ ។

ដោយហេតុផលដូចខ្ញុំបានរៀបរាប់ដ៏វែងនេះ ទើបខ្ញុំសំរេចចិត្តស្វាគមន៍លោក ខៀវ សំផន លោក នួន ជា វិលមករួមរស់ក្នុងសង្គមជាតិ ដើម្បីបញ្ចប់សង្គ្រាម ជំរុញការបង្រួបបង្រួមជាតិ ផ្សះផ្សាជាតិ ហើយក៏ជាការបញ្ចប់អង្គការចាត់តាំងនយោបាយ និង យោធារបស់ខ្មែរក្រហមដែរ ។

ក្នុងលិខិតស្វាគមន៍របស់ខ្ញុំ ក៏ដូចជាលិខិតរបស់ខ្ញុំថ្វាយព្រះមហាក្សត្រ ថ្វាយសម្ដេចក្រុមព្រះ នរោត្តម រណឫទ្ធិ ជូនសម្ដេច ហេង សំរិន គឺនិយាយតែពីសន្តិភាព ការបង្រួបបង្រួមជាតិប៉ុណ្ណោះ មិនបាននិយាយដល់ដំណើរការតុលាការទេ ។ ខ្ញុំមិនបានផ្ដល់ការធានាជូននរណាម្នាក់អោយរួចផុតពីអំណាចតុលាការឡើយ ។ ក្នុងសេចក្ដីថ្លែងការណ៍ផ្ទាល់របស់ខ្ញុំថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៨ ចំពោះ មុខគណៈរដ្ឋមន្ត្រី ខ្ញុំថែមទាំងបាននិយាយថា សូម្បីតែប្រពន្ធខ្ញុំ កូនខ្ញុំ ក៏ខ្ញុំមិនហ៊ានធានាមិនអោយមានការ ចោទប្រកាន់ពីតុលាការដែរ ព្រោះមិនច្បាស់ថា ថ្ងៃក្រោយគេមិនប្រព្រឹត្តិបទល្មើសណាមួយដែលត្រូវតុលាការចោទប្រកាន់ឡើយ ដូច្នេះន័យនេះគ្រប់គ្រាន់ដើម្បីបញ្ជាក់ថា ខ្ញុំគោរពនូវឯករាជ្យភាពរបស់តុលាការ ។

ទាក់ទងនឹងការលើកលែងទោស ឬ ចាប់ខ្លួនលោក ខៀវ សំផន លោក នួន ជា ខ្ញុំសូមបញ្ជាក់ជូនដូចតទៅ ÷

ក/- អ្នកទាំងពីរពុំទាន់មានសាលក្រមតុលាការណាមួយកាត់ទោសគាត់ទេ ដូច្នេះក៏គ្មានការចាំបាច់ដើម្បីសុំការលើកលែងទោស មុនពេលគាត់ចូលមកដែរ ។

ខ/- គ្មានដីការតុលាការណាមួយអោយស្វែងរកការចាប់ខ្លួនអ្នកទាំងពីរឡើយ ។

គ/- អ្នកទាំងពីរស្ម័គ្រចិត្តសុំមករួមរស់ជាមួយសង្គមជាតិវិញ ដោយបោះបង់ចោលនូវការប្រយុទ្ធប្រឆាំងរាជរដ្ឋាភិបាល ។ ពួកគាត់មិនត្រូវបានគេចាប់ខ្លួនក្នុងសមរភូមិប្រយុទ្ធទេ ដូច្នេះពួកគាត់មិនមែនជាឈ្លើយសឹកឡើយ ។

ប្រសិនបើយើងចាប់ខ្លួនគាត់ រាជរដ្ឋាភិបាលរបស់យើងនឹងក្លាយខ្លួនជាមេទ័ពដ៏កំសាក ហើយអត់វិន័យ ដោយចាប់ខ្លួននាយទាហានដែលលើកដៃសារភាព ហើយសុំរស់នៅដោយគ្មានការប្រយុទ្ធតទៅទៀត ។ នេះជាប្រភេទសីលធម៌នៃនាយទាហានដែលខ្លាំងជាមួយអ្នកខ្សោយ ហើយក៏គ្មានទាហានសត្រូវណាផ្សេងទៀតហ៊ានចុះចូលជាមួយរដ្ឋាភិបាលតទៅទៀតដែរ ព្រោះយើងមិនបានគោរពតាមការសន្យារបស់យើង ។ តែការសន្យារបស់យើងក៏មិនបានបំពានលើអំណាចរបស់តុលាការទេ យើងគោរពនូវអំណាចរបស់តុលាការ ។

ជោគជ័យពិតប្រាកដនៃសន្តិភាពមិនមែនសម្លាប់សត្រូវអោយអស់ទាំងពូជនោះទេ តែត្រូវធ្វើអោយសត្រូវឈប់ប្រយុទ្ធដោយសន្តិវិធី ហើយជោគជ័យពិតប្រាកដរបស់រាជរដ្ឋាភិបាល គឺមិនស្ថិតត្រង់យកអ្នកប្រឆាំងគ្រប់ប្រភេទចូលពន្ធនាគារទេ តែត្រូវរកវិធីអោយគេបានចូលរួមកសាងប្រទេស ដើម្បីកាត់បន្ថយភាពក្រីក្រ ។ ការបាត់ស្នូរកាំភ្លើងមិនទាន់មានន័យគ្រប់គ្រាន់ថា មានសន្តិភាពនោះដែរ គឺត្រូវធ្វើអោយមនុស្សគ្រប់រូបគ្មានការភ័យខ្លាច ។ ឯសីលធម៌ និង ផ្លូវច្បាប់ ក៏ពុំគួរបត់បែនតាមកាលៈទេសៈនយោបាយដូចបញ្ហាខ្មែរក្រហមនៅកម្ពុជានេះទេ ។

អ្នកលេងអុកដែលពូកែ គឺជាអ្នកចេះចល័តកូនអុកទាំងហ្វូងគាំទ្រគ្នាពីចំណុចមួយ ទៅចំណុចមួយទៀតដើម្បីទទួលជោគជ័យ ប៉ុន្តែសីលធម៌នៃអ្នកលេងអុកមិនគប្បីត្រូវបានចល័តឡើយ ព្រោះវាជាសារជាតិខាងក្នុងរបស់មនុស្ស ។

សង្ឃឹមថា ការបំភ្លឺរបស់ខ្ញុំគ្រប់គ្រាន់ ដើម្បីយល់ពីអតីតកាល បច្ចុប្បន្ន ក៏ដូចជាអនាគតកាល ៕

*រាជធានីភ្នំពេញ , ថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៩៨*

**ហ៊ុន សែន**